**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** :..................១០៨...........ក.ប/ប.ក

# ប្រកាស
# ស្តីពីការបង្កើតគណៈកម្មការវិនិយោគរបបសន្តិសុខសង្គម
# នៃបេឡាជាតិរបបសន្តិសុខសង្គម

## ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២៩៧/៩១ចុះថ្ងៃទី៣១ខែធ្នូឆ្នាំ១៩៩៧ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការវិនិយោគរបបសន្តិសុខសង្គម នៃបេឡាជាតិរបបសន្តិសុខសង្គម សរសេរជាអក្សរកាត់ "គ.វ.ស.ស." ដើម្បីរៀបចំគោលនយោបាយ និងផែនការវិនិយោគសម្រាប់ដាក់ជូនក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម ពិនិត្យសម្រេច។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤៣៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

**ប្រការ ២.-**

គ.វ.ស.ស. មានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| - នាយកបេឡាជាតិរបបសន្តិសុខសង្គម | ប្រធាន |
| - តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ១ (មួយ) រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ១ (មួយ) រូប | សមាជិក |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ (មួយ) រូប | សមាជិក |
| - តំណាងក្រសួងសុខាភិបាល ១ (មួយ) រូប | សមាជិក |
| - តំណាងនិយោជក ២ (ពីរ) រូប | សមាជិក |
| - តំណាងកម្មករនិយោជិត ២ (ពីរ) រូប | សមាជិក |
| - ប្រធានការិយាល័យ នៃ ប.ស.ស. ១ (មួយ) រូប | លេខាធិការ |

**ប្រការ ៣.-**

សមាជិក នៃគ.វ.ស.ស ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ ៤.-**

ប្រធាន គ.វ.ស.ស. អាចបង្កើតក្រុមការងារជំនាញ ជាជំនួយការ ដើម្បីធ្វើការសិក្សាលើកគម្រោងវិនិយោគ ។

**ប្រការ ៥.-**

ប្រធាន និងសមាជិក នៃ គ.វ.ស.ស ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់អាណត្តិ ៣ (បី) ឆ្នាំ ស្របតាមសំណើរបស់ក្រសួង/ស្ថាប័ន/អង្គភាព ដែលសមាជិកនោះតំណាងឱ្យ ។ អាណត្តិនេះអាចបញ្ចប់ ឬ អាចបន្តទៀតបានតាមសំណើរបស់ក្រសួង/ស្ថាប័នដែលសមាជិកនោះតំណាងឱ្យ ។

សមាជិក គ.វ.ស.ស ត្រូវជ្រើសរើសក្នុងចំណោម មន្ត្រីជំនាញ ឥស្សរៈជន ដែលមានសមត្ថភាព ចំណេះដឹង មានបទពិសោធន៍យ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ក្នុងវិស័យសេដ្ឋកិច្ច ឬសង្គមកិច្ច ឬពាណិជ្ជកម្ម ឬវិស័យច្បាប់ និងមិនត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬ ឧក្រិដ្ឋ ។

**ប្រការ ៦.-**

គ.វ.ស.ស មានភារកិច្ច ដូចតទៅ ៖

- រៀបចំគោលនយោបាយ និងផែនការវិនិយោគរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ដែលមានលក្ខណៈជានីតិវិនិយោគ
- សហការវិនិយោគជាមួយដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ
- គ្រប់គ្រង ចាត់ចែង វាយតម្លៃ ត្រួតពិនិត្យ និងកែលំអកិច្ចការវិនិយោគជាប្រចាំ
- ធ្វើបច្ចុប្បន្នភាពស្តីពីសកម្មភាពវិនិយោគ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់របស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម។

**ប្រការ ៧.-**

លាភការប្រជុំរបស់ គ.រ.ស.ស ជាបន្ទុកចំណាយរបស់បេឡាជាតិរបបសន្តិសុខសង្គម នឹងត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម ។

**ប្រការ ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩.-**

ប្រធានក្រុមប្រឹក្សាភិបាល នៃប.ស.ស. នាយកបេឡាជាតិរបបសន្តិសុខសង្គម ប្រធានអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២០ ខែ ឧសភា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

<u>ចម្លងជូន៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៩
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ